| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | ភាសារខ្មែរ |
| **ប្រធានបទ** | ការស្គាល់តួអក្សរះ<br>-ការប្រើញាណរបស់ខ្លួន ដើម្បីអភិវឌ្ឍបំណិន សមត្ថភាពទាំងប្រាំមួយ។ |
| **ចំណងជើងមេរៀន** | ល្បែងអានសៀវភៅ<br>(ដកស្រង់ពីសៀវភៅរឿងតើនរណាជាអ្នកលាប ពណ៌មេឃ?) |
| **កម្រិត** | មធ្យម ៣០ នាទី |
| **គោលបំណង** | -ការយល់ដឹងអំពីការអាន និងប្រើប្រាស់ឯកសារ សំណេរ ឬឯកសារផ្សេងៗ។ |
| **បំណិនសម្បទា** | -ដឹងពីការកាន់ បើក បិទ អានសៀវភៅរឿង ពីទំព័រមុខរហូតដល់ទំព័រចុងក្រោយបាន ត្រឹមត្រូវ និងយល់ពីអត្ថន័យខ្លឹមសារនៃរឿង។ |
| **ចរិយាសម្បទា** | ស្រឡាញ់ និងចូលចិត្តអានសៀវភៅ។ |
| **គ្រូបង្រៀន** | -ស្វែងរកសៀវភៅឱ្យបានច្រើនដើម្បីអាន ។ |
| **កុមារ** | តាមស្ថានភាពជាក់ស្ដែងនៅពេលអាន។ |
| **រៀបចំ** | -រៀបចំកៅអីទៅតាមចំនួនកុមារ។<br>-ឱ្យកុមារអង្គុយឱ្យបានស្ងៀមស្ងាត់ដើម្បីស្ដាប់គ្រូ អានរឿង ។<br>-បង្កើតសំណួរដើម្បីសួរទៅកាន់កុមារ...។ |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
|---|---|---|
| 1. បង្ហាញក្មេងពីសៀវភៅរឿងដែលត្រូវអានឬទ្បេង។<br>2. ចូរឱ្យក្មេងៗនិយាយតាមពាក្យថា‹សៀវភៅ›។<br>3. ប្រាប់ក្មេងៗពីរបៀបប្រើប្រាស់ និងរបៀបបើកសៀវភៅ ។<br>4. ចូរឱ្យក្មេងៗក្រឡេកមើលទៅលើក្របសៀវភៅនិងឱ្យពួកគេចងចាំរូបភាព និងចំណងជើងរឿងរបស់សៀវភៅដែលត្រូវអាន។<br>5. ពន្យល់ពួកគេពីចំណងជើងនៃរឿងដែលនឹងត្រូវអាន ។<br>6. ចូរឱ្យក្មេងនិយាយតាមពាក្យថា ‹‹ចំណងជើង››<br>7. អានសៀវភៅដោយបង្ហាញរូបភាពយឺតៗនិងច្បាស់ៗទៅកាន់ក្មេងៗ។<br>8. បង្ហាញរូបភាពម្តងទៀតនឹង និយាយអំពីរូបភាពទាំងនោះឱ្យក្មេងៗបានស្គាល់ និងយល់ច្បាស់ពីអត្ថន័យនៃរូបភាព។ | សំណួរមានដូចជាៈ<br>• តើអ្វីដែលមានពណ៌បៃតងនៅក្នុងរឿងនេះ?<br>• តើស្បង់របស់ព្រះសង្ឃមានពណ៌អ្វី?<br>• តើខេទីមកពីប្រទេសណា?<br>• តើអ្នកទាំងអស់គ្នាមានចងចាំទេ ថាតើមួកការពារសុវត្ថិភាពរបស់យ៉េកមានពណ៌អ្វី? | 1. ស្តាប់រឿងដោយយកចិត្តដាក់។<br>2. យកចិត្តទុកដាក់ទៅនឹងរូបភាពដោយកត់ចំណាំសេចក្តីលំអិត។<br>3. ឆ្លើយនឹងសំណួគ្រូរបស់អ្នក ។<br>4. ចូរកុំមានការភ័យខ្លាចឬខ្មាស់អៀននឹងសួរសំណួរទៅកាន់គ្រូរបស់អ្នកប្រសិនបើអ្នកមិនទាន់យល់ច្បាស់។ |

| | | |
|---|---|---|
| 9. ចូរសួរសំណួរដែលបានរៀបចំទាំងនោះ ទៅកាន់ក្មេងៗ<br>10. ឆ្លើយសំណួរណាមួយដែលក្មេងៗមិនយល់។ | | |